**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១៦)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតដែលបានព្យួរកិច្ចសន្យាការងារ ខែកក្កដា ខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២៣ នៃរោងចក្រ ទាំង២១ នៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃសេចក្តីណែនាំលេខ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ នាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ២១ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រទាំង២១ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្ររបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរោងចក្រដទៃផ្សេងទៀត ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

*ថ្ងៃ ពុធ ១៤រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤**

**បញ្ជីឈ្មោះ រោងចក្រ ក្នុងវិស័យកាត់ដេរ**

**ចំនួន ២១ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| វិស័យកាត់ដេរ | | 21 |
| 1 | ក្រុមហ៊ុន ជេអេដាប់បែលយូ ( J.A.W ) | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ស៊ីកូ (ភ្នំពេញ) ខូអិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ស៊ីផេក ហ្វាម៉ិន (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន យ៉ុងដេវ៉ឺ ហ្វាមេន ភីធីវ៉ាយ អិលធីឌី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ហេន7 ហ្វាម៉ិន ឯ.ក (ទីតាំងពោធិ៍សែនជ័យ) | ភ្នំពេញ |
| 6 | ក្រុមហ៊ុន អិម ធី យេស៍ ហ្វាមេន (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ទ្រីលាន ហ្វាមេន (ខេមបូឌា) ឯ. ក | ភ្នំពេញ |
| 8 | ក្រុមហ៊ុន សប្លេនឌីដ ឆេន អ៊ិនធើណេសិនណល | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ហ្វ្រេត យូញៀន(ខេមបូឌា)ហ្វាមេនខូអិល | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ហ៊ី លី តូ នីតធីង ខូ អិលធីឌី | ភ្នំពេញ |
| 11 | ក្រុមហ៊ុន វីនក្រោន (ខេមបូឌា) អិនដាសស្រ្ទៀល | កំពង់ស្ពឺ |
| 12 | ក្រុមហ៊ុន ហ៊ែនថុន ឡាក់ហ្គេដ (ខេមបូឌា) ឯ ក | កំពង់ស្ពឺ |
| 13 | ក្រុមហ៊ុន ញូខាំមើ ឡាក់ហ្គេដ អេនប៊ែក (ខេមបូឌា) | កំពង់ស្ពឺ |
| 14 | ក្រុមហ៊ុន ហេង ស៊ីម ហ្វ៊ូត វែរ ឯ.ក | កំពង់ស្ពឺ |
| 15 | ក្រុមហ៊ុន ស៊ុន ខេង ហ្វាមេន (ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 16 | ក្រុមហ៊ុន ហ៊ុង ហ៊ីង មេធល មេនូហ្វេធើរី (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 17 | ក្រុមហ៊ុន ស៊ីអេស ហ្គោលវេ ថេកស្ទាយ (ខេមបូឌា) | តាកែវ |
| 18 | ក្រុមហ៊ុន អេចស៊ី គ្លូប៊ល ថេកស្ទាយ ឯ.ក | តាកែវ |
| 19 | ក្រុមហ៊ុន ស៊ូភើ លីង ហ្វេសិន (ខេមបូឌា)ឯ.ក | កំពង់ឆ្នាំង |
| 20 | ក្រុមហ៊ុន ស៊ីកូ (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 21 | ក្រុមហ៊ុន ធី.ខេ ហ្វាមេន ស៊ីសុផុន | បន្ទាយមានជ័យ |